# ភាពក្រីក្ររបស់កុមារ
# នៅកម្ពុជា៖
# ឯកសារសង្ខេប



ក្រសួងផែនការ

SPRI

SOCIAL POLICY RESEARCH INSTITUTE

unicef

ដើម្បីកុមារគ្រប់រូប

**អ្នកនិពន្ធ៖**
ជូលៀ កាប៉ាទី, លៀន ប៊ូន, គ្រិស ណឺបួក
វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយសេដ្ឋកិច្ច / វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយសង្គម

**រចនាដោយ៖**
ក្រុមហ៊ុនក្រាហ្វិករូត

**កែសំរួល៖**
ណារ៉មី លីន

**ក្រុមត្រួតពិនិត្យបច្ចេកទេស៖**
- ឯកឧត្តម ថេង បញ្ញាធន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋានផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ
- ឯកឧត្តម ប៉ូច សុវណ្ណឌី អគ្គនាយករង អគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ
- លោកស្រី ម៉ាគី កាតូ ប្រធានអង្គភាពគោលនយោបាយសង្គម អង្គការយូនីសេហ្វ
- លោក ជា វិបុល អ្នកឯកទេសគោលនយោបាយសង្គម អង្គការយូនីសេហ្វ

# ១. សេចក្តីផ្តើម

ជាមួយនឹងការផ្តល់សច្ចាប័នអនុសញ្ញាស្តីពីសិទ្ធិកុមារ និងការអនុម័តទទួលយកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ប្រទេសកម្ពុជាបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការសម្រេចឱ្យបាននូវសិទ្ធិរបស់កុមារ។ ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាភាពក្រីក្ររបស់កុមារមានសារៈសំខាន់និងចាំបាច់ ដើម្បីបំពេញសិទ្ធិទាំងនេះ ដោយហេតុថា ភាពក្រីក្រអាចបង្កគ្រោះថ្នាក់ដល់កុមារច្រើនបែបច្រើនយ៉ាង ដូចជាបង្កផលប៉ះពាល់ដល់លទ្ធភាពទទួលបានការសិក្សា ទឹកស្អាតនិងអនាម័យ និងអាហារូបត្ថម្ភឱ្យបានសមស្របសម្រាប់ពួកគេ នេះគ្រាន់តែនិយាយអំពីការលំបាកមួយចំនួនតូចប៉ុណ្ណោះ ក្នុងចំណោមការលំបាកជាច្រើនដែលកុមារត្រូវជួបប្រទះ។

ស្របជាមួយនឹងរបៀបវារៈអភិវឌ្ឍន៍ជាសកល និងដោយមានការទទួលស្គាល់ថា ភាពក្រីក្ររបស់កុមារ គឺជាស្ថានភាពពិសេស ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ដោយឡែករាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ការវិភាគលើភាពក្រីក្ររបស់កុមារ គឺជាមធ្យោបាយដ៏សំខាន់សម្រាប់វាយតម្លៃលទ្ធផលដែលសម្រេចបានចេញពីរបៀបវារៈកាត់បន្ថយភាពក្រក្ររបស់ខ្លួន។ ការវាយតម្លៃលើបញ្ហាប្រឈមក្នុងការកាត់បន្ថយភាពក្រីក្រដោយផ្តោតលើកុមារ ផ្តល់នូវព័ត៌មានស៊ីជម្រៅសំខាន់ៗអំពីលក្ខណៈនៃភាពក្រីក្រនៅកម្ពុជា ពោលគឺ – តើអ្នកណាខ្លះជាជនក្រីក្រ ហេតុអ្វីបានជាពួកគេបន្តមានជីវភាពក្រីក្រម និងថាតើភាពក្រីក្រផ្ទេរឆ្លងជំនាន់ដោយរបៀបណា ជាដើម។ ការស្វែងយល់ពីបរិបទបច្ចុប្បន្ននៃភាពក្រីក្ររបស់កុមារ និងការកំណត់ទិន្នន័យដើមគ្រាសម្រាប់វាយតម្លៃវឌ្ឍនភាព ដែលសម្រេចបាននាពេលអនាគត គឺជាកត្តាចាំបាច់បំផុត ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០។

ឯកសារនេះបង្ហាញពីលទ្ធផលសំខាន់ៗនៃការសិក្សាលើភាពក្រីក្ររបស់កុមារនៅកម្ពុជា ដែលធ្វើការពិនិត្យលើភាពក្រីក្រផ្អែកតាមហិរញ្ញវត្ថុឬការចំណាយ (monetary) និងភាពក្រីក្រពហុសមាសភាគ (multidimensional) ដែលកុមារអាយុពី 0ដល់ ១៧ ឆ្នាំជួបប្រទះ។ កុមារត្រូវបានគេចាត់ទុកថា មានភាពក្រីក្រផ្អែកតាមការចំណាយ នៅពេលដែលកុមាររស់នៅក្នុងគ្រួសារដែលការប្រើប្រាស់សរុបរបស់គ្រួសារក្នុងមនុស្សពេញវ័យម្នាក់ មានកម្រិតទាបជាងបន្ទាត់នៃភាពក្រីក្រផ្អែកតាមចំណាយថ្នាក់ជាតិ។ កុមារត្រូវបានចាត់ទុកថា មានភាពក្រីក្រពហុសមាសភាព ប្រសិនបើកុមារជួបការលំបាក ពាក់ព័ន្ធនឹងសុខុមាលភាពរបស់ខ្លួនច្រើនបែបច្រើនយ៉ាងទៅតាមកម្រិតកំណត់នៃភាពធ្ងន់ធ្ងររបស់ភាពក្រី។

ការវិភាគនេះធ្វើឡើងដោយប្រើប្រាស់ទិន្នន័យរដ្ឋាភិបាលឆ្នាំ ២០១៤៖ ពោលគឺទិន្នន័យដែលបានពីការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CSES) ដើម្បីវាយតម្លៃភាពក្រីក្រផ្អែកតាមចំណាយ និងការអង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជាសម្រាប់វាយតម្លៃភាពក្រីក្រពហុសមាសភាគ។

ការសិក្សាស្តីពីភាពក្រីក្ររបស់កុមារនៅកម្ពុជា ដោយប្រើប្រាស់វិធីសាស្រ្តវាយតម្លៃពហុសមាសភាគ និងផ្អែកតាមការចំណាយ ជួយឱ្យគេអាចវាស់វែងកាន់តែជាក់លាក់ និងយល់ដឹងកាន់តែល្អប្រសើរអំពីស្ថានភាពរបស់កុមារនៅកម្ពុជា។ខណៈពេលដែលការវាស់វែងភាពក្រីក្រផ្អែកតាមចំណាយផ្តោតលើការវាយតម្លៃមធ្យោបាយហិរញ្ញវត្ថុគិតជាមធ្យមដែលគ្រួសាររបស់កុមារមានការវាយតម្លៃលើភាពក្រីក្រពហុសមាសភាគ ធ្វើការកំណត់ថាតើមានការបំពេញតម្រូវការជាមូលដ្ឋានរបស់កុមារដែរឬទេ ដោយមិនគិតពីកម្រិតនៃប្រាក់ចំណូល។ ការវិភាគដោយឡែកពីគ្នាលើទស្សនទាននៃភាពក្រីក្រទាំងពីរប្រភេទនេះជួយឱ្យគេដឹងកាន់តែពេញលេញពីស្ថានភាពពិតប្រាកដរបស់កុមារនៅកម្ពុជា និងកំណត់ដឹងពីអត្តសញ្ញាណអនុក្រុមកុមារដែលងាយរងគ្រោះជាងគេដែលទាមទារឱ្យមានការអនុវត្តគោលនយោបាយ និងកម្មវិធីដែលមានលក្ខណៈពិសេសសម្រាប់ពួកគេ។

# ២. ភាពក្រីក្ររបស់កុមារផ្អែកតាមហិរញ្ញវត្ថុ ឬការចំណាយ៖ លទ្ធផលរកឃើញសំខាន់ៗ

**តារាងទី ១** បង្ហាញពីលទ្ធផលនៃការវិភាគភាពក្រីក្រផ្អែកតាម ចំណាយរបស់កុមារកម្ពុជា ដោយបែងចែកទៅតាមតំបន់ភូមិសាស្រ្ត។ ការប្រៀបធៀបភាពក្រីក្ររបស់កុមារផ្អែកតាមចំណាយ បែងចែកតាមភូមិសាស្រ្ត បែបនេះ មានប្រយោជន៍ព្រោះគេអាចកំណត់ដឹងពីតំបន់ភូមិសាស្រ្តអាទិភាព ដែលនាំឱ្យកម្មវិធីអភិវឌ្ឍន៍នានា អាចផ្តោតចំតំបន់ដែលក្រីក្រ។

**តារាងទី ១៖ ភាពក្រីក្រផ្អែកតាមចំណាយជារួមសម្រាប់កុមារអាយុ ០-១៧ ឆ្នាំ នៅកម្ពុជា និងកម្រិតនៃភាពក្រីក្របែងចែកតាមតំបន់ភូមិសាស្រ្ត**

| ថ្នាក់ក្រោមជាតិ | អត្រានៃភាពក្រីក្ររាប់តាមចំនួនមនុស្ស (% នៃប្រជាជនក្រីក្រ) | គម្លាតនៃភាពក្រីក្រ | ភាពធ្ងន់ធ្ងរនៃភាពក្រីក្រ | របាយកុមារក្រីក្រតាមតំបន់ (% នៃភាពក្រីក្រក្នុងសន្ទស្សន៍នៃភាពក្រីក្រគិតតាមចំនួនមនុស្ស) | របាយចំនួនកុមារសរុប(%) |
|---|---|---|---|---|---|
| តំបន់ | | | | | |
| តំបន់វាលទំនាប | ១៥,៥ | ២,៩ | ០,៩ | ៤២,៨ | ៤៤,១ |
| ទន្លេសាប | ១៥,៧ | ៣,០ | ០,៩ | ៣៤,៤ | ៣៥,១ |
| តំបន់ឆ្នេរ | ១៥,៥ | ២,៦ | ០,៦ | ៧,២ | ៧,៤ |
| តំបន់ខ្ពង់រាប និង ជួរភ្នំ | ១៨,៧ | ៣,៧ | ១,១ | ១៥,៧ | ១៣,៤ |
| **សរុប** | **១៦,០** | **៣,០** | **០,៩** | **១០០,០** | **១០០,០** |

**តារាងទី២**បង្ហាញពីសន្ទស្សន៍ភាពក្រីក្ររួមសម្រាប់កុមារអាយុ០-១៧ឆ្នាំនៅកម្ពុជាបែងចែកតាមភេទ និងក្រុមអាយុ។កុមារា និងកុមារីពុំបានបង្ហាញពីភាពខុសប្លែកគ្នាខ្លាំងឡើយ បើគិតជាចំនួនកុមារដែលរស់នៅក្នុងភាពក្រីក្រ និងទទួលបានពិន្ទុភាពធ្ងន់ធ្ងរនៃភាពក្រីក្រជារួមស្មើគ្នា។ ដោយឡែកគេសង្កេតឃើញថា អត្រានៃភាពក្រីក្រគិតតាមចំនួនមនុស្ស មានកម្រិតខ្ពស់ក្នុងចំណោមកុមារតូចៗអាយុ ០-៤ ឆ្នាំ ពោលគឺ ១៧% បើធៀបនឹងកុមារអាយុច្រើន (១៦,២% សម្រាប់កុមារអាយុ ៥-១៤ ឆ្នាំ និង ១៣,៩% សម្រាប់ក្មេងជំទង់អាយុ ១៥-១៧ ឆ្នាំ)។

## តារាងទី ២៖ ភាពក្រីក្រផ្អែកតាមចំណាយជារួមសម្រាប់កុមារអាយុ ០-១៧ ឆ្នាំ បែងចែកតាមភេទ និងក្រុមអាយុ

| ថ្នាក់ក្រោមជាតិ | អត្រានៃភាពក្រីក្រ រាប់តាមចំនួនមនុស្ស (% នៃប្រជាជនក្រីក្រ) | គម្លាតនៃភាពក្រីក្រ | ភាពធ្ងន់ធ្ងរនៃភាពក្រីក្រ | របាយកុមារក្រីក្រតាមតំបន់ (% នៃភាពក្រីក្រក្នុងសន្ទស្សន៍នៃភាពក្រីក្រគិតតាមចំនួនមនុស្ស) | របាយចំនួនកុមារសរុប(%) |
|---|---|---|---|---|---|
| **ភេទ** | | | | | |
| ប្រុស | ១៦,៣ | ៣,១ | ០,៩ | ៥២,២ | ៥១,២ |
| ស្រី | ១៥,៧ | ៣,០ | ០,៩ | ៤៧,៨ | ៤៨,៨ |
| **ក្រុមអាយុ** | | | | | |
| ០-៤ ឆ្នាំ | ១៧,០ | ៣,២ | ០,៩ | ៣០,៩ | ២៩,១ |
| ៥-១៤ ឆ្នាំ | ១៦,២ | ៣,១ | ០,៩ | ៥៣,៦ | ៥៣,០ |
| ១៥-១៧ ឆ្នាំ | ១៣,៩ | ២,៦ | ០,៨ | ១៥,៥ | ១៧,៩ |
| **សរុប** | **១៦,០** | **៣,០** | **០,៩** | **១០០,០** | **១០០,០** |

**តារាងទី ៣** បង្ហាញព័ត៌មានអំពីរង្វាស់ភាពក្រីក្រទៅតាមលក្ខណៈសមាជិកគ្រួសារនៅកម្ពុជាក្នុងឆ្នាំ ២០១៤។ តារាងនេះបង្ហាញយ៉ាងច្បាស់ថា នៅពេលដែលគ្រួសារ និងសមាជិកកាន់តែច្រើន នោះកុមារក្នុងគ្រួសារនោះកាន់តែក្រ។ លើសពីនេះនៅពេលដែលចំនួនកុមារក្នុងគ្រួសាមួយមានការកើនឡើង កុមារនៅក្នុងគ្រួសារនោះរឹតតែក្រ។

## តារាងទី ៣៖ ផលធៀបតាមចំនួនមនុស្សបែងចែកទៅតាមសមាសភាគប្រជាសស្ត្រ

| | អត្រាភាពក្រីក្រកុមារ | របាយចំនួនកុមារក្រីក្រ | របាយចំនួនកុមារ |
|---|---|---|---|
| **ចំនួនកុមារអាយុ ០-៤ ឆ្នាំ** | | | |
| ០ នាក់ | ១២,៥ | ៣៨,០ | ៤៨,៧ |
| ១ | ១៦,៨ | ៤១,៣ | ៣៩,៣ |
| ២ | ២៦,០ | ១៧,៤ | ១០,៨ |
| ៣ ឬចាប់ពី ៣នាក់ឡើងទៅ | ៤១,៧ | ៣,២ | ១,២ |
| **សរុប** | | | |
| **ទំហំគ្រួសារ** | | | |
| ១ | ០,០ | ០,០ | ០,០ |
| ២ | ១១,៤ | ២៥,០ | ៣៥,១ |
| ៣ | ១៧,០ | ២៨,០ | ២៦,៤ |
| ៤ | ២៣,៤ | ១៩,៤ | ១៣,៣ |
| ៥ | ៤២,៨ | ១៣,១ | ៤,៩ |
| ៦ | ៤១,៦ | ៤,៨ | ១,៨ |
| ៧ ឬចាប់ពី ៧ នាក់ឡើងទៅ | ៥៥,៥ | ២,១ | ០,៦ |
| **សរុប** | **១៦,០** | **១០០,០** | **១០០,០** |

តារាងទី ៤ ប្រៀបធៀបអត្រាភាពក្រីក្ររាប់តាមចំនួនមនុស្សផ្អែកតាមបន្ទាត់នៃភាពក្រីក្រផ្លូវការបច្ចុប្បន្ន និងអត្រានៃភាពក្រីក្រគិតតាមបន្ទាត់នៃភាពក្រីក្រជាជម្រើសផ្សេងទៀត ដែលអាចលើស និងក្រោមបន្ទាត់នៃភាពក្រីក្រផ្លូវការបច្ចុប្បន្ន ២០%។ ទិន្នន័យនេះបង្ហាញថា អត្រាភាពក្រីក្រផ្អែកតាមចំណាយរបស់កុមារនៅកម្ពុជា ងាយប្រែប្រួលខ្លាំង ទៅតាមជម្រើសនៃបន្ទាត់ភាពក្រីក្រ។ ទិន្នន័យនេះបង្ហាញថា ប្រជាពលរដ្ឋមួយភាគធំ ទំនងជាប្រមូលផ្តុំក្រោមបន្ទាត់នៃភាពក្រីក្រ ក៏ដូចជា ងាយរងគ្រោះខ្លាំងក្នុងការធ្លាក់ចូលទៅក្នុង ក៏ដូចជារួចផុតពីភាពក្រីក្រ។ លទ្ធផលនេះរំលេចឱ្យឃើញពីភាពចាំបាច់ក្នុងការធ្វើការវិភាគឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតលើភាពក្រីក្រពហុសមាសភាគរបស់កុមារ។

## តារាងទី ៤៖ ភាពងាយប្រែប្រួលនៃរង្វាស់ភាពក្រីក្រទៅតាមជម្រើសបន្ទាត់នៃភាពក្រីក្រ

| | អត្រានៃភាពក្រីក្រ | | គម្លាតនៃភាពក្រីក្រ | | ភាពធ្ងន់ធ្ងរនៃភាពក្រីក្រ | |
|---|---|---|---|---|---|---|
| | អត្រាភាពក្រីក្ររាប់តាមចំនួនមនុស្ស | ប្រែប្រួលពីតួលេខជាក់ស្តែង (%) | គម្លាតនៃភាពក្រីក្រ | ប្រែប្រួលពីតួលេខជាក់ស្តែង (%) | ភាពធ្ងន់ធ្ងរនៃភាពក្រីក្រ | ប្រែប្រួលពីតួលេខជាក់ស្តែង (%) |
| ជាក់ស្តែង(ប្រើប្រាស់ខ្សែបន្ទាត់ក្រីក្របច្ចុប្បន្ន) | ១៦,០ | ០,០ | ៣,០ | ០,០ | ០,៩ | ០,០ |
| +៥% | ១៩,៥ | ២១,៥ | ៣,៧ | ២៣,០ | ១,១ | ២៥,៧ |
| +១០% | ២២,៧ | ៤១,៦ | ៤,៥ | ៤៩,០ | ១,៤ | ៥៥,៤ |
| +២០% | ៣០,១ | ៨៧,៥ | ៦,៤ | ១០៨,៨ | ២,០ | ១២៧,១ |
| -៥% | ១៣,៣ | -១៧,២ | ២,៤ | -២០,០ | ០,៧ | -២២,១ |
| -១០% | ១០,៩ | -៣១,៨ | ១,៩ | -៣៧,៤ | ០,៥ | -៤០,៧ |
| -២០% | ៦,៤ | -៥៩,៩ | ១,១ | -៦៤,៦ | ០,៣ | -៦៨,៥ |

# ៣. ភាពក្រីក្រពហុសមាសភាគរបស់កុមារៈ លទ្ធផលរកឃើញសំខាន់ៗ

## វិធីសាស្ត្រ

វិធីសាស្ត្រវាស់វែង ភាពក្រីពហុសមាសភាគប្រើប្រាស់ក្នុងការសិក្សានេះ ធ្វើឡើងផ្អែកទៅតាមវិធីសាស្ត្រវិភាគពីការខ្វះខាតចម្រុះដែលអាចត្រួតគ្នា (Multiple OverlappingDeprivation Analysis-MODA) ដែលត្រូវបានបង្កើតឡើងដោយយូនីសេហ្វ ដើម្បីផ្តល់នូវក្របខ័ណ្ឌមួយ ដែលគេអាចវាស់វែង កំណត់បរិមាណ និង កំណត់អត្តសញ្ញាណភាពក្រីក្រ និងការខ្វះខាតដែលកុមារជួបប្រទះ។ វិធីសាស្ត្រនេះផ្តោតលើការវាស់ វែងការខ្វះខាតរបស់កុមារ និងមានសមាសភាគសំខាន់ៗដូចខាងក្រោមៈ

១. វិធីសាស្ត្រនេះចាត់ទុកកុមារជាឯកតានៃការវិភាគ ពោលគឺមិនមែនយកគ្រួសារមកធ្វើជាឯកតានៃការវិភាគឡើយ

២. វិធីសាស្ត្រនេះប្រើប្រាស់ទិន្នន័យនៅកម្រិតបុគ្គលនៅពេលដែលអាចធ្វើបាន ដើម្បីឱ្យគេអាចប្រៀបធៀបភាពខុសប្លែកគ្នារវាងយេនឌ័រមួយ និងយេនឌ័រមួយទៀត រវាងក្រុមអាយុមួយនិងក្រុមអាយុមួយទៀត និងរវាងសមាជិកម្នាក់ និងសមាជិកម្នាក់ទៀតនៅក្នុងគ្រួសារតែមួយ

៣. វិធីសាស្ត្រនេះប្រើប្រាស់អភិក្រមវដ្តជីវិត (life-cycle approach) ដោយធ្វើការផ្លាស់ប្តូរសូចនាករទៅតាមការផ្លាស់ប្តូរតម្រូវការរបស់កុមារ នៅដំណាក់កាលអាយុខុសៗគ្នា

៤. វិធីសាស្ត្រនេះពង្រីកវិសាលភាពនៃអភិក្រមតាមវិស័យ តាមរយៈការវិភាគលើការខ្វះខាត ដែលត្រួតគ្នា

៥. វិធីសាស្ត្រនេះបញ្ចូលប្រេវ៉ាឡង់ និងភាពស៊ីជម្រៅនៃភាពខ្វះខាតដែលកុមារម្នាក់ៗជួបប្រទះ ដែលអាចបង្ហាញពីកុមារងាយរងគ្រោះជាងគេ ដែលជួបភាពខ្វះខាតក្នុងចំនួនច្រើនក្នុងពេលតែមួយ និង

៦. វិធីសាស្ត្រនេះបង្កើតនូវកម្រងព័ត៌មានបង្ហាញពីលក្ខណៈភូមិសាស្ត្រ និងលក្ខណៈសង្គម សេដ្ឋកិច្ចរបស់កុមារដែលជួបការខ្វះខាត (ចម្រុះ) ដែលផ្តល់លទ្ធភាពឱ្យគេអាចរៀបចំការឆ្លើយតប និងអន្តរាគមន៍គោលនយោបាយកាន់តែចំក្រុមគោលដៅ និងកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

ការខ្វះខាតត្រូវបានបែងចែកជាប្រាំបីប្រភេទធំៗ - អាហារូបត្ថម្ភ សុខភាព ការអភិវឌ្ឍកុមារតូច ការអប់រំ ទឹកស្អាត អនាម័យ លំនៅដ្ឋាន និងព័ត៌មាន។ មានសមាសភាគរហូតដល់ប្រាំមួយត្រូវបានជ្រើសរើសសម្រាប់ក្រុមអាយុនីមួយៗ (០-៤ ឆ្នាំ, ៥-១៤ ឆ្នាំ, ១៥-១៧ ឆ្នាំ) ផ្អែកតាមភាពពាក់ព័ន្ធ និងភាពអាចរកបាននៃទិន្នន័យ។

កុមារនៅកម្ពុជាភាគច្រើនជួបការខ្វះខាតចម្រុះដោយភាគច្រើនជួបប្រទះនឹងការខ្វះខាតពីរឬបីសមាសភាគក្នុងពេលតែមួយ (រូបភាពទី ១)។ ការខ្វះខាតបែបនេះមានភាពខុសប្លែកគ្នាគួរឱ្យកត់សម្គាល់រវាងតំបន់ជនបទ និងតំបន់ប្រជុំជន។

# តួលេខសំខាន់ៗ

## រូបភាពទី ១៖ របាយនៃការខ្វះខាតនៅថ្នាក់ជាតិ និងបែងចែកតាមកន្លែងរស់នៅរបស់កុមារអាយុ ០-១៧ ឆ្នាំ




រូបភាពទី ២ បញ្ជាក់ថា កុមារភាគច្រើននៅកម្ពុជាជួបប្រទះនឹងការខ្វះខាតចម្រុះ និងបង្ហាញផងដែរពីតួនាទីរបស់ទីតាំងភូមិសាស្ត្រ ពោលគឺប្រជុំជនធៀបនឹងជនបទ និងភេទ របស់កុមារ។ ខណៈពេលដែលនៅតំបន់ប្រជុំជនមានកុមារត្រឹមតែ ១១,៨% ប៉ុណ្ណោះ ដែលជួបការខ្វះខាតយ៉ាងហោចណាស់បីសមាសភាគក្នុងពេលតែមួយ អត្រានេះខ្ពស់រហូតដល់ ៥៤,៣% នៅតំបន់ជនបទ។ កុមារដែលរស់នៅតំបន់ខ្ពង់រាប និងជួរភ្នំ គឺជាក្រុមដែលជួបការខ្វះខាតច្រើនជាងគេ ពោលគឺ ៦៦,៩%។ ពុំមានការសង្កេតឃើញភាពខុសប្លែកគ្នាទៅតាមភេទរបស់កុមារនោះឡើយ។

## រូបភាពទី ២៖ ការជួបប្រទះនឹងការខ្វះខាតពហុសមាសភាគរាប់តាមចំនួនមនុស្ស (ជួបការខ្វះខាតក្នុងសមាសភាគយ៉ាងហោចណាស់ចំនួនបីក្នុងពេលតែមួយ) បែងចែកតាមថ្នាក់ជាតិ កន្លែងរស់នៅ តំបន់ភូមិសាស្ត្រ និងភេទរបស់កុមារអាយុ ០-១៧ ឆ្នាំ




ផ្នែកខាងក្រោមធ្វើការវិភាគលម្អិតបន្ថែមទៀតពីការខ្វះខាត ដែលកុមារក្នុងក្រុមអាយុទាំងបី៖ ០-៤ ឆ្នាំ, ៥-១៤ ឆ្នាំ និង ១៥-១៧ ឆ្នាំ ជួបប្រទះ។

# ៣.១ កុមារអាយុ ០-៤ ឆ្នាំ

## ចំណុចសំខាន់ៗ

- នៅក្នុងក្រុមអាយុនេះ មានកុមារ ៥៧% កំពុងរស់នៅក្នុងភាពក្រីក្រពហុសមាសភាគ ដែលជួបប្រទះនឹងការខ្វះខាតជាមធ្យម ៣,៩ ប្រភេទក្នុងចំណោមការខ្វះខាតទាំងប្រាំមួយសមាសភាគ។
- កុមាររស់នៅក្នុងតំបន់ជនបទ និងនៅភូមិភាគឦសាននៃប្រទេសកម្ពុជាទំនងជាមានអត្រាជួបការខ្វះខាតខ្ពស់ជាងគេក្នុងគ្រប់សមាសភាគទាំងអស់ ហើយទំនងជាជួបនឹងការខ្វះខាតច្រើនចម្រុះក្នុងពេលតែមួយ។
- ការព្រួយបារម្ភចម្បងសម្រាប់កុមារកម្ពុជាក្នុងក្រុមអាយុនេះ គឺជាការព្រួយបារម្ភពាក់ព័ន្ធនឹងការអភិវឌ្ឍកុមារតូច និងអាហារូបត្ថម្ភ។ ក្នុងចំណោមកុមារ ១០ នាក់ មាន ៨ នាក់ ដែលពុំបានទទួលការអប់រំកុមារតូច ឬចូលរួមក្នុងកម្មវិធីមត្តេយ្យសិក្សា ខណៈពេលដែលកុមារ ៤៧,៤% ពុំបានទទួលអាហារទៅតាមតម្រូវការអាហារសម្រាប់ទារក និងកុមារតូច។
- អាហារូបត្ថម្ភ ការអភិវឌ្ឍកុមារតូច និងលំនៅដ្ឋានបញ្ចូលគ្នាបង្ហាញពីភាពត្រួតគ្នាខ្ពស់បំផុតសម្រាប់កុមារអាយុ ០-៤ ឆ្នាំ។ កុមារប្រមាណ ១៨% ជួបការខ្វះខាតក្នុងគ្រប់សមាសភាគទាំងបី ខណៈពេលដែលកុមារតែ ១៣% ពុំបានជួបនឹងការខ្វះខាតក្នុងសមាសភាគមួយណាក្នុងចំណោមសមាសភាគទាំងបីដែលត្រូវបានវិភាគ។
- នៅថ្នាក់ជាតិ សមាសភាគអនាម័យ និងលំនៅដ្ឋានរួមចំណែកខ្ពស់ជាងគេដល់អត្រាភាពក្រីក្រពហុសមាសភាគ ដែលត្រូវបានកែសម្រួលទៅតាមកម្រិតនៃការខ្វះខាត (Mo) ដោយសមាសភាគអនាម័យរួមចំណែក ២១,៧% និងសមាសភាគលំនៅដ្ឋានរួមចំណែក ២១,៣%។ នៅតំបន់ជនបទ គេអាចសង្កេតឃើញលទ្ធផលស្រដៀងគ្នានេះ ខណៈដែលនៅតំបន់ ប្រជុំជន សមាសភាគលំនៅដ្ឋាន និងសមាសភាគអភិវឌ្ឍន៍កុមារតូចមានតួនាទីសំខាន់ជាងគេ។

## ការវិភាគលើការខ្វះខាតតែមួយប្រភេទ

សម្រាប់កុមារអាយុ ០-៤ ឆ្នាំ មានការវាយតម្លៃលើស មាសភាគចំនួនប្រាំមួយ ផ្អែកតាមភាពពាក់ព័ន្ធ និងភាពអាចរកបាននៃទិន្នន័យ៖ សុខភាព អាហារូបត្ថម្ភ ការអភិវឌ្ឍកុមារតូច ទឹកស្អាត អនាម័យ និងលំនៅដ្ឋាន។

លទ្ធផលនេះបង្ហាញពីការខ្វះខាតក្នុងអត្រាខ្ពស់ស្ទើរតែគ្រប់សូចនាករទាំងអស់ សម្រាប់កុមារអាយុ ០-៤ ឆ្នាំ នៅកម្ពុជា (រូបភាពទី ៣)។ ចំណុចគួរឱ្យកត់សម្គាល់ក្នុងចំណោមកុមារ ១០ នាក់ក្នុងក្រុមអាយុនេះ មាន ៨ នាក់ ដែលពុំបានចូលរួមក្នុងកម្មវិធីអប់រំកុមារតូច ឬកម្មវិធីមត្តេយ្យសិក្សា (៨១,៨%)។ ដោយឡែកនៅកម្រិតសមាសភាគវិញ អត្រានៃការខ្វះខាតខ្ពស់បំផុតត្រូវបានសង្កេតឃើញក្នុងចំណោមកុមារអាយុ ០-៤ ឆ្នាំ បើធៀបនឹងក្រុមអាយុដទៃទៀត ជាពិសេសក្នុងសមាសភាគអភិវឌ្ឍន៍កុមារតូច ដោយមានកុមារ ៧១,១% ជួបនឹងការខ្វះខាតបែបនេះ (រូបភាពទី ៤)។ លើសពីនេះ កុមារ ៤៧,៤% ក្នុងក្រុមអាយុនេះជួបការខ្វះខាតខាងសមាសភាគអាហារូបត្ថម្ភ។ ការខ្វះខាតបែបនេះ អាចមានន័យថា នាំឱ្យមានផលវិបាកធ្ងន់ធ្ងរដល់ការអភិវឌ្ឍកាយសម្បទា និងអាចចំពោះការអភិវឌ្ឍបញ្ញាស្មារតីដល់កុមារតូចៗ ក្នុងភាគរយមួយខ្ពស់នៅកម្ពុជា ដែលជាលក្ខខណ្ឌស្នូល សម្រាប់ការអភិវឌ្ឍធនធានមនុស្ស។

សូចនាករនៅកម្រិតគ្រួសារភាគច្រើន បង្ហាញពីអត្រាជួបការខ្វះខាត ស្រដៀងគ្នានេះដែរ នៅក្នុងក្រុមអាយុទាំងបីក្រុម។ ក្នុងចំណោមកុមារ ១០ នាក់ មានប្រមាណ ៥ នាក់ដែលពុំមានបង្គន់ដែលត្រូវបានកែលម្អប្រើប្រាស់ និងមានកុមារម្នាក់ក្នុងចំណោម ៧ នាក់រស់នៅក្នុងគ្រួសារ ដែលមានកម្រាល ដំបូល និង/ឬជញ្ជាំង ដែលពុំត្រូវបានកែលម្អ។ ស្ថានភាពបរិស្ថានទាំងនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់បំពេញសមាសភាគផ្សេងទៀតនៃសុខុមាលភាពរបស់កុមារ និងបង្ហាញពីជីវភាពរស់នៅទាបរបស់គ្រួសារដែលរងផលប៉ះពាល់។ ឧទាហរណ៍ បើទោះបីជាកុមារបានទទួលអាហារហូបចុកគ្រប់គ្រាន់យ៉ាងណាក៏ដោយ ការលាងសម្អាតដៃ បរិក្ខារអនាម័យពុំគ្រប់គ្រាន់ក្នុងអត្រាមួយខ្ពស់ និងការប្រើប្រាស់ឥន្ធនៈរឹងសម្រាប់ចម្អិនអាហារ ធ្វើឱ្យកុមារទាំងនេះប្រឈមនឹងគ្រោះថ្នាក់ក្នុងបរិស្ថាន ដែលមានគ្រោះថ្នាក់ ដល់សុខភាព និងសុខុមាលភាពរបស់ពួកគេ។

## រូបភាពទី ៣៖ អត្រានៃការជួបការខ្វះខាតរាប់តាមចំនួនមនុស្ស (%) បែងចែកតាមសូចនាករ និងសមាសភាគ កុមារអាយុ ០-៤ ឆ្នាំ




## រូបភាពទី ៤៖ អត្រានៃការជួបការខ្វះខាតរាប់តាមចំនួនមនុស្ស (%) បែងចែកតាមសមាសភាគ កុមារអាយុ ០-៤ ឆ្នាំ



## ការវិភាគលើការខ្វះខាតត្រួតគ្នាផ្ទួនៗ

*រូបភាពទី ៥* បង្ហាញពីទិដ្ឋភាពជារួមនៃភាពក្រីក្រពហុសមាសភាគ ដែលកុមារអាយុ ០-៤ ឆ្នាំ ជួបប្រទះ។ រូបភាពទី ៦ និងទី ៧ បំបែកទិន្នន័យនេះលម្អិតទៅតាមភូមិសាស្ត្រ ពោលគឺតាមតំបន់ និងភូមិភាគ។ កុមារភាគច្រើនក្នុងចំណោមកុមារទាំងនេះជួបប្រទះនឹងភាពក្រីក្រពហុសមាសភាគ។ របាយដែលបង្ហាញពីការជួបការខ្វះខាតរបស់កុមារ ដែលរស់នៅតំបន់ជនបទមានការកើនឡើងដល់កម្រិតអតិបរមា សម្រាប់ការជួបការខ្វះខាតផ្ទួនៗគ្នាចំនួនបី (២៥,៣%) ហើយកុមារ ៦៣% ដែលរស់នៅតំបន់ជនបទជួបការខ្វះខាតចាប់ពី ៣ សមាសភាគឡើងទៅក្នុងពេលជាមួយគ្នា ខណៈពេលដែលកុមារភាគច្រើនដែលរស់នៅតាមតំបន់ប្រជុំជនជួបការខ្វះខាតក្នុងសមាសភាគមួយ ឬពុំជួបការខ្វះខាតសោះតែម្តង (*រូបភាពទី ៦*)។ កុមារនៅភូមិភាគឦសាននៃប្រទេសកម្ពុជាជួបការខ្វះខាតក្នុងកម្រិតមួយខ្ពស់ជាងកុមារដែលរស់នៅភាគខាងត្បូង ឬភាគខាងលិចនៃប្រទេសកម្ពុជា (*រូបភាគទី ៧*)។

### រូបភាពទី ៥ របាយនៃការជួបការខ្វះខាតនៅទូទាំងប្រទេស សម្រាប់កុមារអាយុ ០-៤ ឆ្នាំ




### រូបភាពទី ៦៖ របាយនៃការជួបការខ្វះខាតបែងចែកតាមតំបន់សម្រាប់កុមារអាយុ ០-៤ ឆ្នាំ




### រូបភាពទី ៧៖ របាយនៃការជួបការខ្វះខាត បែងចែកតាមភូមិភាគ កុមារអាយុ ០-៤ ឆ្នាំ




** សញ្ញាផ្កាយ (*) បង្ហាញថា ភាពខុសប្លែកគ្នារវាងអត្រានៃការជួបការខ្វះខាតរបស់ប្រភេទរងមានលក្ខណៈគួរឱ្យកត់សម្គាល់តាមបែបស្ថិតិ ជាមួយនឹងកម្រិត p<0.0៥.*

**រូបភាពទី ៨ និងទី ៩** បង្ហាញទិន្នន័យពីការជួបការខ្វះខាតផ្ទួនៗពាក់ព័ន្ធនឹងអាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យសម្រាប់តំបន់ជនបទធៀបនឹងតំបន់ប្រជុំជន និងក្រុមដែលជួបបញ្ហាក្រិសក្រិនធៀបជាមួយនឹងក្រុមដែលពុំជួបបញ្ហាក្រិសក្រិន។ បើធៀបជាមួយនឹងតំបន់ជនបទ ចំនួនកុមារដែលជួបការខ្វះខាតផ្នែកអាហារូបត្ថម្ភ មានកម្រិតខ្ពស់នៅតំបន់ប្រជុំជន ហើយចំនួនកុមារដែលជួបការខ្វះខាតផ្នែកទឹក និងអនាម័យមានចំនួនតិចជាងទៅវិញ។ ភាពត្រួតគ្នារវាងសមាសភាគទាំងនេះមានកម្រិតខ្ពស់នៅតំបន់ជនបទ (មានកុមារ ១១,៨% ជួបការខ្វះខាតក្នុងគ្រប់សមាសភាគទាំងអស់) ដោយឡែកការជួបការខ្វះខាតរបស់ពួកគេមានលក្ខណៈពិសេសជាងនៅតំបន់ប្រជុំជន (១,៧%)។

## រូបភាពទី ៨៖ ការខ្វះខាតត្រួតគ្នាផ្ទួនៗចំនួនបីសម្រាប់សមាសភាគអាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យបញ្ចូលគ្នាសម្រាប់កុមារអាយុ 0-៤ ឆ្នាំ បែងចែកតាមតំបន់






*រូបភាពទី ៩* បង្ហាញពីចំនួនកុមារ ដែលជួបការខ្វះខាតផ្នែកអាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ ក៏ដូចជា កម្រិតដែលពួកគេជួបនឹងការខ្វះខាតទាំងនេះផ្ទួនៗបញ្ចូលគ្នា ដែលបង្ហាញថា ការជួបការខ្វះខ្វាតមានកម្រិតខ្ពស់សម្រាប់កុមារដែលមានបញ្ហាក្រិសក្រិន បើធៀបជាមួយនឹងកុមារដែលពុំមានបញ្ហាក្រិសក្រិន។ តួលេខទាំងនេះបង្ហាញពីភាពចាំបាច់ ដែលគេត្រូវធ្វើការពិចារណាអនុវត្តអន្តរាគមន៍លើសពីត្រឹមតែផ្តោតលើអាហារូបត្ថម្ភ ដែលមានគោលបំណងត្រឹមតែកាត់បន្ថយបញ្ហាក្រិសក្រិនរបស់កុមារ។

## រូបភាពទី ៩៖ ការជួបការខ្វះខាតផ្ទួនៗចំនួនបី ពាក់ព័ន្ធនឹងទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ សម្រាប់កុមារអាយុ ០-៤ ឆ្នាំ បែងចែកទៅតាមស្ថានភាពក្រិសក្រិន






## ៣.២ កុមារអាយុ ៥-១៤ ឆ្នាំ

### ចំណុចសំខាន់ៗ

- ៤៤,២% នៃកុមារក្នុងក្រុមអាយុនេះមានភាពក្រីក្រពហុសមាសភាគ ពោលគឺក្នុងចំណោមការខ្វះខាតចំនួនប្រាំ ជាមធ្យម កុមារទាំងនេះជួបប្រទះនឹងការខ្វះខាតចំនួន ៣,៦។
- កុមាររស់នៅតំបន់ជនបទ និងតំបន់ខ្ពង់រាប និងជួរភ្នំមានស្ថានភាពលំបាកជាងគេ។ ឧទាហរណ៍ ៥៧,៨% នៃកុមាររស់នៅតំបន់ខ្ពស់រាប និងតំបន់ជួរភ្នំ ជួបការខ្វះខាតក្នុងគ្រប់សមាភាគទាំងប្រាំ ដែលត្រូវបានវិភាគ។
- កុមារកម្ពុជាអាយុ ៥-១៤ ឆ្នាំប្រមាណពាក់កណ្តាលពុំមានបង្គន់ដែលត្រូវបានកែលម្អប្រើប្រាស់ឡើយ ខណៈពេលដែលកុមារ ៤៧% កំពុងរស់នៅក្នុងផ្ទះដែលមានមនុស្សរស់នៅកកកុញ ពោលគឺមានមនុស្សជាង ៤ នាក់ក្នុងបន្ទប់គេងមួយ។ លើសពីនេះការទទួលបានការអប់រំកម្រិតបឋមសិក្សា ត្រូវការការយកចិត្តទុកដាក់ ពោលគឺកុមារលើសអាយុចូលរៀនបឋមសិក្សា ( ១២-១៤ ឆ្នាំ ) ៤៤,៦% ពុំបានរៀនចប់ប្រាំមួយថ្នាក់ នៅកម្រិតបឋមសិក្សាឡើយ។
- ចាំបាច់ត្រូវមានការប្រើប្រាស់វិធីសាស្រ្តអន្តរវិស័យសម្រាប់ឆ្លើយតបចំពោះភាពត្រួតគ្នាក្នុងកម្រិតខ្ពស់រវាងការជួបការខ្វះខាតផ្នែកលំនៅដ្ឋាន និងការជួបការខ្វះខាតផ្នែកអនាម័យ។
- នៅគ្រប់កម្រិតទាំងអស់ ( ថ្នាក់ជាតិ តំបន់ជនបទ និងប្រជុំជន ) លំនៅដ្ឋាន និងអនាម័យ បង្កផលប៉ះពាល់ធ្ងន់ធ្ងរជាងគេមកលើអត្រានៃភាពក្រីក្រពហុសមាសភាគរាប់តាមចំនួនមនុស្ស ដែលត្រូវបានកែសម្រួលទៅតាមកម្រិតធ្ងន់ធ្ងរនៃភាពក្រីក្រ (Mo)។

### ការវិភាគលើការជួបការខ្វះខាតតែមួយ

មានការវាយតម្លៃលើសមាសភាគចំនួនប្រាំសម្រាប់កុមារ អាយុ ៥-១៤ ឆ្នាំ ផ្អែកទៅតាមភាពពាក់ព័ន្ធ និងភាពអាចរកបាននៃទិន្នន័យ៖ ការអប់រំ ទឹក អនាម័យ លំនៅដ្ឋាន និងព័ត៌មាន។

រូបភាពទី ១០ និងទី ១១ បង្ហាញពីការជួបការខ្វះខាតក្នុងអត្រាខ្ពស់ចំពោះសូចនាករជាច្រើន ចំពោះកុមារអាយុ ៥-១៤ ឆ្នាំ នៅកម្ពុជា។ កុមារក្នុងក្រុមអាយុនេះជួបប្រទះនឹងអត្រានៃការជួបការខ្វះខាតរាប់តាមចំនួនមនុស្សក្នុងកម្រិតខ្ពស់ជាងគេក្នុងសមាសភាគលំនៅដ្ឋាននៅកម្រិតគ្រួសារ ដោយសារតែអត្រាជួបការខ្វះខាតខ្ពស់ក្នុងសូចនាករ ដែលបង្ហាញពីការរស់នៅកកកុញ (៤៧,0%) និងសូចនាករ ដែលបង្ហាញពីការប្រើប្រាស់ឥន្ធនៈរឹងសម្រាប់ចម្អិនអាហារ (៣៤,៤%)។ កុមារអាយុ ៥-១៤ ឆ្នាំជិតពាក់កណ្តាល( ៤៩,៧% ) ពុំមានបង្គន់អនាម័យ ដែលត្រូវបានកែលម្អប្រើប្រាស់ឡើយ។ លើសពីនេះ កុមារ ៦១,៦% ពុំបានទទួលសេវាអនាម័យប្រកបដោយសុវត្ថិភាព ដែលត្រូវបានកែលម្អនៅកម្រិតសមាសភាគនេះឡើយ ដែលស្ថានភាពនេះស្រដៀងគ្នានឹងអត្រាជួបការខ្វះខាតរបស់កុមារអាយុ ១៥-១៧ ដែរ។ កុមារក្នុងក្រុមអាយុជិតពាក់កណ្តាល ( ៤២,៥% ) ខ្វះការទទួលបានព័ត៌មានឱ្យបានគ្រប់គ្រាន់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

កុមារអាយុ ៥-១៤ ឆ្នាំ ២២,៥% ជួបការខ្វះខាតក្នុងសមាសភាគអប់រំ ដែលទំនងជាកើតឡើងដោយសារអត្រាខ្ពស់នៃការមិនបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សាក្នុងចំណោមកុមារ ដែលលើសអាយុចូលរៀននៅបឋមសិក្សា (អាយុ ១២, ១៣, ១៤ ឆ្នាំ) និងដោយសារតែកុមារ ១៦,៨% ក្នុងក្រុមអាយុនេះមានអាយុច្រើនជាងអាយុដែលត្រូវចូលរៀន ចាប់ពីពីរឆ្នាំឡើយទៅ។ នេះគឺជាការព្រួយបារម្ភ ដោយហេតុថា បើទោះបីជាអត្រាចុះឈ្មោះចូលរៀនជាមូលដ្ឋានមានកម្រិតខ្ពស់យ៉ាងណាក៏ដោយ មានកុមារមួយភាគធំ ដែលពុំបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សាសមស្របទៅតាមអាយុរបស់ពួកគេ។ នេះបង្ហាញពីចំណុចខ្សោយនៃគុណភាពរបស់សាលារៀននៅកម្ពុជា ដែលធ្វើឱ្យកុមារមិនអាចឡើងទៅរៀននៅកម្រិតថ្នាក់ខ្ពស់សមស្របទៅនឹងអាយុរបស់ពួកគេ ឬបង្ហាញពីជីវភាពរស់នៅ ដែលធ្វើឱ្យកុមារពុំអាចបញ្ចប់ការសិក្សាបាន ដូចជា ចំណូលរបស់គ្រួសារទាបការជ្រើសរើសរវាងទៅរៀន ឬធ្វើការ ឬការចុះឈ្មោះចូលរៀនលើសអាយុជាដើម។ ការសម្រេចលទ្ធផលទាបនៃសូចនាករអប់រំក៏អាចមានទំនាក់ទំនងជាមួយនឹងការផ្តល់សេវាអភិវឌ្ឍន៍កុមារតូច ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយពុំទាន់គ្រប់គ្រាន់ផងដែរ

ដូចជា ការខ្វះការផ្តល់អាហារឱ្យបានគ្រប់គ្រាន់នៅវ័យកុមារតូច ដែលនាំឱ្យកុមារកាន់តែជួបការលំបាកក្នុងការរៀនសូត្រ នៅពេលដែលកុមារទាំងនេះទៅរៀននៅសាលា។ អត្រាជួបការលំបាកក្នុងសូចនាករនៅកម្រិតគ្រួសារ ដូចជា សមាសភាគលំនៅដ្ឋាន អនាម័យ និងទឹកជាដើម គឺមានកម្រិតខ្ពស់ស្រដៀងគ្នានឹងអត្រារបស់ក្រុមអាយុផ្សេងទៀតផងដែរ។

### រូបភាពទី ១០៖ អត្រានៃការជួបការខ្វះខាតរាប់តាមចំនួនមនុស្ស (%) បែងចែកតាមសូចនាករ កុមារអាយុ ៥-១៤ ឆ្នាំ



## រូបភាពទី ១១៖ អត្រានៃការជួបការខ្វះខាតរាប់តាមចំនួនមនុស្ស (%) បែងចែកតាមសមាសភាគ កុមារអាយុ ៥-១៤ ឆ្នាំ




## ការវិភាគការជួបការខ្វះខាតចម្រុះ

**រូបភាពទី ១២** បង្ហាញពីរូបភាពជារួមនៃភាពក្រីក្រពហុសមាសភាគក្នុងចំណោមកុមារអាយុ ៥-១៤ ឆ្នាំ។ រូបទី ១៣ និងរូបភាពទី ១៤ បែងចែកទិន្នន័យនេះលម្អិតទៅតាមតំបន់ និងទីតាំងភូមិសាស្ត្រ។ កុមារភាគច្រើននៅក្នុងក្រុមអាយុនេះ ជួបប្រទះនឹងការខ្វះខាតចម្រុះ។ ពាក់កណ្តាលនៃកុមារកម្ពុជាទាំងអស់ ក្នុងក្រុមអាយុនេះជួបការខ្វះខាតពីពីរទៅបីសមាសភាគក្នុងពេលតែមួយ។ ការជួបការខ្វះខាតរបស់កុមារនៅតំបន់ប្រជុំជន និងតំបន់ជនបទ មានលក្ខណៈខុសប្លែកគ្នាឆ្ងាយ និងមានការប្រែប្រួលទៅតាមតំបន់ភូមិសាស្ត្រ។

### រូបភាពទី ១២៖ របាយនៃការជួបការខ្វះខាតនៅកម្រិតនៃប្រទេសកម្ពុជាទាំងមូល សម្រាប់កុមារអាយុ ៥-១៤ ឆ្នាំ




### រូបភាពទី ១៣៖ របាយនៃការជួបការខ្វះខាតបែងចែកតាមតំបន់ប្រជុំ ឬតំបន់ជនបទ សម្រាប់កុមារអាយុ ៥-១៤ ឆ្នាំ




** សញ្ញាផ្កាយ (*) បង្ហាញថា ភាពខុសប្លែកគ្នារវាងអត្រាជួបការខ្វះខាតនៃប្រភេទវងមានលក្ខណៈគួរឱ្យកត់សម្គាល់ តាមន័យស្ថិតិនៅកម្រិត* $p<0.05$

## រូបភាពទី ១៤៖ របាយនៃការជួបការខ្វះខាតបែងចែកតាមតំបន់ភូមិសាស្ត្ររបស់កុមារ អាយុ ៥-១៤ ឆ្នាំ




** សញ្ញាផ្កាយ ( * ) បង្ហាញថា ភាពខុសប្លែកគ្នារវាងអត្រាជួបការខ្វះខាតនៃប្រភេទរងមានលក្ខណៈគួរឱ្យកត់សម្គាល់តាមន័យស្ថិតិនៅកម្រិត $p<0.05$*

**រូបភាពទី ១៥** ពិនិត្យលើវិសាលភាពដែលការជួបការខ្វះខាតក្នុងសមាសភាគអប់រំ ទឹក និងលំនៅដ្ឋាន បង្កផលប៉ះពាល់ដល់កុមារអាយុ ៥-១៤ ឆ្នាំ នៅកម្ពុជា នៅថ្នាក់ជាតិ តំបន់ប្រជុំជន និងតំបន់ជនបទ។ រូបភាពនេះបង្ហាញថា លទ្ធផលនៃថ្នាក់ជាតិទទួលរងឥទ្ធិពលខ្លាំង ដោយសារលទ្ធផលនៅកម្រិតតំបន់ជនបទ។ នៅពេលបញ្ចូលសមាសភាគអប់រំ ទឹក និងលំនៅដ្ឋានបញ្ចូលគ្នា ការជួបការខ្វះខាតក្នុងសមាសភាគទាំងបីនេះ មានភាពត្រួតគ្នារឹតតែខ្លាំង បើធៀបនឹងតំបន់ប្រជុំជន។

## រូបភាពទី ១៥៖ ពិនិត្យលើវិសាលភាពដែលការជួបការខ្វះខាតក្នុងសមាសភាគអប់រំ ទឹក និងលំនៅដ្ឋាន បង្កផលប៉ះពាល់ដល់កុមារអាយុ ៥-១៤ ឆ្នាំ នៅកម្ពុជា នៅថ្នាក់ជាតិ តំបន់ប្រជុំជន និងតំបន់ជនបទ



## ៣.៣ កុមារអាយុ ១៥-១៧ ឆ្នាំ

### ចំណុចសំខាន់ៗ

- អត្រានៃការជួបការខ្វះខាតរាប់តាមចំនួនមនុស្សសម្រាប់កុមារអាយុ ១៥-១៧ ឆ្នាំនៅកម្ពុជា មានកម្រិតខ្ពស់បំផុតសម្រាប់សមាសភាគអប់រំ និងលំនៅដ្ឋាន។ កុមារជិត ៦០% នៃក្រុមអាយុនេះរៀនយឺតជាងកម្រិតថ្នាក់ស្របតាមអាយុរបស់ខ្លួន ចាប់ពីពីរឆ្នាំឡើងទៅ ខណៈពេលដែលមានកុមារអាយុ ១៥ ឆ្នាំ ប្រមាណ ៤៣% ពុំបានចូលរៀនសោះតែម្តង។ លើសពីនេះក្នុងចំណោមកុមារ ១០ នាក់ មានជាងបួននាក់កំពុងរស់នៅក្នុងផ្ទះ ដែលមានមនុស្សរបស់នៅកកកុញ ពោលគឺមានមនុស្សជាងបួននាក់ក្នុងបន្ទប់គេងមួយ។
- កុមារក្នុងក្រុមអាយុនេះពាក់កណ្តាលមានភាពក្រីក្រពហុសមាសភាគ ដោយពួកគេជួបនឹងការខ្វះខាតជាមធ្យម ៣,៧ សមាសភាគ។
- សមាសភាគអប់រំ អនាម័យ និងលំនៅដ្ឋានត្រួតគ្នាក្នុងកម្រិតខ្ពស់ជាងគេ (៣២%) នៃភាពត្រួតគ្នាបីសមាសភាគ ដែលអាចមានទាំងអស់សម្រាប់កុមារអាយុ ១៥-១៧ ឆ្នាំ។
- នៅតំបន់ប្រជុំជន សមាសភាគទឹកពុំសូវពាក់ព័ន្ធឡើយ បើធៀបនឹងតំបន់ជនបទ។ ទោះជាយ៉ាងណាក៏ដោយ សមាសភាគអប់រំ និងលំនៅដ្ឋានរួមចំណែកច្រើនជាងគេដល់អត្រាជួបការខ្វះខាតពហុសមាសភាគរាប់តាមចំនួនមនុស្ស (Mo) នៅថ្នាក់ជាតិ កម្រិតតំបន់ប្រជុំជន និងតំបន់ជនបទ។

### ការវិភាគលើការជួបការខ្វះខាតតែមួយ

មានការវាយតម្លៃលើសមាសភាគចំនួនប្រាំសម្រាប់កុមារអាយុ ១៥-១៧ ឆ្នាំ ផ្អែកតាមភាពពាក់ព័ន្ធ និងភាពអាចរកបាននៃទិន្នន័យ៖ ការអប់រំ ទឹកស្អាត អនាម័យ លំនៅដ្ឋាន និងព័ត៌មាន។

*រូបភាពទី ១៦* បង្ហាញពីការជួបការខ្វះខាតក្នុងអត្រាខ្ពស់ក្នុងស្ទើរតែគ្រប់សូចនាករទាំងអស់សម្រាប់កុមារអាយុ ១៥-១៧ ឆ្នាំនៅកម្ពុជា។ ចំណុចគួរឱ្យភ្ញាក់ផ្អើលអត្រានៃការជួបការខ្វះខាតក្នុងសមាសភាគអប់រំមានកម្រិតខ្ពស់លើសលុប និងពុំសមស្របដើម្បីឱ្យមានការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាពឡើយ។ រូបភាពទី ១៧ បង្ហាញថា កុមារកម្ពុជាអាយុ ១៥-១៧ ចំនួន៦៥,៨% ជួបការខ្វះខាតក្នុងសមាសភាគអប់រំ ដោយកុមារជិត ៦០% រៀនយឺតជាងកម្រិតថ្នាក់សមស្របតាមអាយុរបស់ពួកគេចាប់ពីពីរឆ្នាំឡើងទៅ និងកុមារដែលដល់អាយុចូលរៀនកម្រិតមូលដ្ឋាន ៤៣,២% ពុំបានចូលរៀនឡើយ និងក្នុងចំណោមកុមារបីនាក់ ដែលលើសអាយុចូលរៀននៅបឋមសិក្ស មានប្រហែលម្នាក់ពុំបានបញ្ចប់ការអប់រំនៅកម្រិតបឋមសិក្សា។ គួរឱ្យកត់សម្គាល់កុមារអាយុ ១៥-១៧ ឆ្នាំជាច្រើននាក់ជួបការខ្វះខាតក្នុងសមាសភាគអប់រំ បើធៀបនឹងកុមារអាយុ ៥-១៤ ឆ្នាំ (៦៥,៨% ធៀបនឹង ២២,៥%) ដូចដែលបង្ហាញក្នុងផ្នែកមុននេះ។ លទ្ធផលទាំងនេះបង្ហាញពីអត្រាខ្ពស់នៃការបោះបង់ចោលការសិក្សា – ពោលគឺកុមារដែលអាយុលើសពីអាយុរៀននៅបឋមសិក្សា អាចឆាប់បោះបង់ចោលការសិក្សា ឬពុំបានរៀនចប់កម្រិតបឋមសិក្សា។

## រូបភាពទី ១៦៖ អត្រានៃការជួបការខ្វះខាតរាប់តាមចំនួនមនុស្ស (%) បែងចែកតាមសូចនាករ កុមារអាយុ ១៥-១៧ ឆ្នាំ



### រូបភាពទី ១៧៖ អត្រានៃការជួបការខ្វះខាតរាប់តាមចំនួនមនុស្ស (%) បែងចែកតាមសមាសភាគ កុមារអាយុ ១៥-១៧ ឆ្នាំ




## ការវិភាគការជួបការខ្វះខាតចម្រុះ

**រូបភាពទី ១៨** បង្ហាញពីរូបភាពជារួមនៃភាពក្រីក្រពហុសមាសភាគរបស់កុមារអាយុ ១៥-១៧ ឆ្នាំ ដោយបង្ហាញថា កុមារភាគច្រើនជួបនឹងការខ្វះខាតពហុសមាសភាគ។ ក្នុងចំណោមកុមារ ១០នាក់ មានតែម្នាក់ប៉ុណ្ណោះ ដែលពុំជួបការខ្វះខាត។ កុមាររស់នៅតំបន់ជនបទ ទំនងជាជួបនឹងការខ្វះខាតចម្រុះច្រើនជាងកុមារនៅតំបន់ប្រជុំជន (រូបភាពទី ១៩)។ របាយនៃការជួបការខ្វះខាតរបស់កុមារ ដែលរស់នៅតំបន់ជនបទកើនឡើងដល់កម្រិតខ្ពស់បំផុតក្នុងសមាសភាគចំនួនបី ខណៈពេលដែលកុមារភាគច្រើនរស់នៅតំបន់ប្រជុំជនជួបនឹងការខ្វះខាតក្នុងសមាសភាគមួយ ឬពុំជួបការខ្វះខាតតែម្តង។ រូបទី ២០ បង្ហាញពីលទ្ធភាពដែលកុមាររស់នៅតំបន់ខ្ពង់រាប និងតំបន់ជួរភ្នំជួបនឹងការខ្វះខាតចម្រុះក្នុងកម្រិតខ្ពស់ បើធៀបនឹងកុមារដែលរស់នៅតំបន់វាលទំនាប។

### រូបភាពទី ១៨៖ របាយនៃការជួបការខ្វះខាតនៅកម្រិតនៃប្រទេសកម្ពុជាទាំងមូល សម្រាប់កុមារអាយុ ១៥-១៧ ឆ្នាំ




### រូបភាពទី ១៩៖ របាយនៃការជួបការខ្វះខាតបែងចែកតាមតំបន់ប្រជុំ ឬតំបន់ជនបទ សម្រាប់កុមារអាយុ ១៥-១៧




** សញ្ញាផ្កាយ (*) បង្ហាញថា ភាពខុសប្លែកគ្នារវាងអត្រាជួបការខ្វះខាតនៃប្រភេទរងមាន លក្ខណៈគួរឱ្យកត់សម្គាល់តាមន័យស្ថិតិនៅកម្រិត p<0.0៥*

## រូបភាពទី ២០៖ របាយនៃការជួបការខ្វះខាតបែងចែកតាមតំបន់ភូមិសាស្ត្ររបស់កុមារអាយុ ១៥-១៧ ឆ្នាំ




** សញ្ញាផ្កាយ ( * ) បង្ហាញថា ភាពខុសប្លែកគ្នារវាងអត្រាជួបការខ្វះខាតនៃប្រភេទវងមានលក្ខណៈគួរឱ្យកត់សម្គាល់តាមន័យស្ថិតិនៅកម្រិត $p$<0.0៥*

**រូបភាពទី ២១** បង្ហាញពីរបាយនៃការជួបការខ្វះខាតរបស់ក្មេងស្រីអាយុ ១៥-១៧ ឆ្នាំ ទៅតាមស្ថានភាពអាពាហ៍ពិពាហ៍របស់ពួកគេ។ ក្មេងស្រីដែលរៀបការ ឬធ្លាប់រៀបការហើយ ជួបការខ្វះខាតក្នុងសមាសភាគយ៉ាងហោចណាស់ក៏មួយដែរ ក្នុងពេលតែមួយ បើធៀបនឹងក្មេងស្រី ១១,៩% ពុំធ្លាប់រៀបការ ដែលពុំជួបការខ្វះខាតក្នុងសមាសភាគណានោះ។

## រូបភាពទី ២១៖ របាយនៃការជួបការខ្វះខាត បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍របស់ក្មេងស្រីសម្រាប់ក្មេងស្រីអាយុ ១៥-១៧ ឆ្នាំ




** សញ្ញាផ្កាយ ( * ) បង្ហាញថា ភាពខុសប្លែកគ្នារវាងអត្រាជួបការខ្វះខាតនៃប្រភេទវងមានលក្ខណៈគួរឱ្យកត់សម្គាល់តាមន័យស្ថិតិនៅកម្រិត $p$<0.0៥*

**រូបភាពទី ២២** បង្ហាញពីភាពត្រួតគ្នានៃការជួបការខ្វះខាតក្នុងសមាសភាគអប់រំ អនាម័យ និងលំនៅដ្ឋានសម្រាប់កុមារអាយុ ១៥-១៧ ឆ្នាំ ដោយពិចារណាពីភាពខុសប្លែកគ្នារវាងតំបន់ប្រជុំជន និងតំបន់ជនបទ។ ភាពក្រីក្រពហុសមាសភាគគឺជាបញ្ហាដែលស្តែងចេញយ៉ាងច្បាស់នៅតំបន់ជនបទ – ពោលគឺមិនត្រឹមតែករណីជួបការខ្វះខាតក្នុងសមាសភាគនីមួយៗខ្ពស់ជាងនៅក្នុងតំបន់ជនបទប៉ុណ្ណោះទេ លើសពីនេះ កុមារច្រើនដែលជួបការខ្វះខាតក្នុងសមាសភាគនីមួយៗ ទំនងជាជួបការខ្វះខាតក្នុងសមាសភាគយ៉ាងហោចណាស់មួយផ្សេងទៀតផងដែរ។ គោលនយោបាយដែលផ្តោតលើការជួបការខ្វះខាតក្នុងសមាសភាគណាមួយក្នុងចំណោមសមាសភាគទាំងនេះ ត្រូវប្រើប្រាស់អភិក្រមអន្តរវិស័យទៅតាមស្ថានភាពចាំបាច់ជាក់ស្តែង។

## រូបភាពទី ២២៖ ភាពត្រួតគ្នានៃការជួបការខ្វះខាតបីសមាសភាគសម្រាប់សមាសភាគអប់រំ អនាម័យ និងលំនៅដ្ឋានបញ្ចូលគ្នាសម្រាប់កុមារអាយុ ១៥-១៧ ឆ្នាំ បែងចែកតាមតំបន់ប្រជុំជន ឬតំបន់ជនបទ






# ៤. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការវិភាគភាពក្រីក្រផ្អែកតាមហិរញ្ញវត្ថុ ឬតាមការចំណាយ និងការវិភាគភាពក្រីក្រពហុសមាសភាគទាំងនេះបង្ហាញថា ដើម្បីឱ្យកុមារនៅកម្ពុជា ទទួលបានសុខុមាលភាពត្រូវតែមានការឆ្លើយតបចំពោះភាពក្រីក្រក្នុងទម្រង់ទាំងពីរនេះ។ ចំណុចនេះពាក់ព័ន្ធជាមួយនឹងនឹងការសម្រេចគោលដៅរងទាំងពីរនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ១.២ – ពោលគឺត្រឹមឆ្នាំ ២០៣០ កាត់បន្ថយឱ្យបានពាក់កណ្តាលនូវភាពក្រីក្រផ្អែកតាមចំណាយ និងភាពក្រីក្រ "ក្នុងគ្រប់ទម្រង់ទាំងអស់" សម្រាប់កុមារ ដោយប្រើប្រាស់និយមន័យរបស់ប្រទេស (តារាងទី ៥)។ ការលុបបំបាត់ភាពក្រីក្រផ្អែកតាមចំណាយ ឬភាពក្រីក្រពហុសមាសភាគតែមួយទំនងជានាំឱ្យមាន ការទុកចោលក្រុមកុមារដែលក្រីក្រដោយសារកត្តាទាំងពីរ ឬកត្តាណាមួយ។ បើទោះបីជាភាពក្រីក្រផ្អែកតាម ចំណាយត្រូវបានលុបបំបាត់ត្រឹមឆ្នាំ ២០៣០ ក៏ដោយ ក៏មានកុមារក្នុងភាគរយមួយខ្ពស់ នៅបន្តខ្វះលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន និងនៅមានតម្រូវការដែលពុំត្រូវបានបំពេញ ដែលមានសារៈសំខាន់ចាំបាច់សម្រាប់ការលូតលាស់ និងការអភិវឌ្ឍរបស់ពួកគេ ក៏ដូចជា សំខាន់សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចរយៈពេលវែងប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។

សម្រាប់កុមារ យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ គួរធ្វើយ៉ាងណានាំមកនូវការផ្លាស់ប្តូរក្នុងវិស័យជាច្រើន ដែលមានសារៈសំខាន់ចំពោះសុខុមាលភាពរបស់កុមារ ដោយការសម្រេចគោលដៅនេះត្រូវធ្វើឱ្យបានក្នុងពេលតែមួយ។ កុមារម្នាក់ដែលជួបការខ្វះខាតផ្អែកអាហារូបត្ថម្ភ និងអនាម័យ បើទោះបីជាបានទទួលអនាម័យគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏នៅមានការអភិវឌ្ឍយឺតយ៉ាវប្រសិនបើបញ្ហាអាហារូបត្ថម្ភពុំត្រូវបានឆ្លើយតបនោះទេ។ លទ្ធផលរកឃើញទាំងនេះទាមទារឱ្យមានការអនុវត្តអភិក្រមពហុវិស័យគ្រប់ជ្រុងជ្រោយប្រសើរជាងមុនសម្រាប់ឆ្លើយតបចំពោះតម្រូវការរបស់កុមារ។ ជាពិសេសសម្រាប់អនុក្រុមកុមារមួយចំនួន ដូចជា កុមាររស់នៅតំបន់ជនបទ ឬកុមារដែលមានបញ្ហាក្រិសក្រិនជាដើម យុទ្ធសាស្រ្តដែលមានការសម្របសម្រួលពហុវិស័យមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឆ្លើយតបចំពោះការខ្វះខាតដែលកើតឡើងព្រមគ្នាទាំងនេះ។ ការវិភាគលើលក្ខណៈនៃភាពក្រីក្រដែលបង្ហាញខាងដើម បានកំណត់ផងដែរ នូវក្រុមកុមារដែលងាយរងគ្រោះជាងគេ បង្ហាញព័ត៌មានមួយចំនួន អំពីរបៀបរៀបចំយន្តការជ្រើសរើសក្រុមគោលដៅឱ្យរឹតតែមានប្រសិទ្ធភាពបន្ថែមទៀត។

### តារាងទី ៥៖ អត្រាសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ១.២.១ និង ១.២.២ សម្រាប់កុមារ

| គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព | ប្រភេទ | សូចនាករ គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព | បន្ទាត់នៃភាពក្រីក្រ | ២០១៥ | ២០៣០ |
|---|---|---|---|---|---|
| | | | | អត្រានៃភាពក្រីក្រ | |
| | | | | ដើមគ្រា | ចំណុចដៅ |
| ១.២.១ | *ភាពក្រីក្រផ្អែកតាមចំណាយ (និយមន័យរបស់ជាតិ)* | % នៃកុមាររស់ នៅក្រោមបន្ទាត់នៃភាពក្រីក្ររបស់ជាតិ | បន្ទាត់នៃភាពក្រីក្រនៅថ្នាក់ជាតិរបស់កម្ពុជា = ៤.៩៨៤ រៀល/ថ្ងៃ | ១៦,០% | ៨,០% |
| ១.២.២ | *ភាពក្រីក្រពហុសមាសភាគ (និយមន័យរបស់ជាតិ)* | % កុមារដែលជួបការខ្វះខាតពហុសមាសភាគទៅតាមនិយមន័យរបស់ជាតិ | ការជួបការខ្វះខាតក្នុងសមាសភាគយ៉ាងហោចណាស់ចំនួនបីពាក់ព័ន្ធនឹងសុខុមាលភាពរបស់កុមារ | ៤៨,៧% | ២៤,៤% |

**ក្រសួងផែនការ**

ផ្ទះលេខ 386 មហាវិថីព្រះមុនីវង្ស
រាជធានីភ្នំពេញ ប្រទេសកម្ពុជា

**មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ( យូនីសេហ្វ )**

ជាន់ទី ៥ អគារ អិចឆេនស្ក័រ លេខ ១៩&២០
ផ្លូវលេខ ១០៦ រាជធានីភ្នំពេញ ប្រទេសកម្ពុជា